អង្គភាពសវនកម្មផ្ទៃក្នុង

INTERNAL AUDIT UNIT

អត្ថបទប្រចាំខែ

លេខ ២៥/២៤ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២៤

# ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ

## និយមន័យនៃការគ្រប់គ្រងហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុ សំដៅដល់វិធីសាស្ត្រនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់អង្គភាព/ ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពតាមរយៈការធ្វើផែនការ ការរកប្រភពធនធាន ការបែងចែកធនធាន ការត្រួតពិនិត្យការប្រើប្រាស់ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ស្ថាប័ន។ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព បុគ្គលទទួលបន្ទុកត្រូវមានការរៀបចំផែនការថវិកា ការអនុវត្តថវិកា ការរៀបចំរបាយការណ៍ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្មខាងក្នុង និងខាងក្រៅ។



ទន្ទឹមនឹងនេះ បុគ្គលទទួលបន្ទុកហិរញ្ញវត្ថុត្រូវតែពិចារណា អំពីស្ថានភាពហិរញ្ញវត្ថុទូទៅរបស់ស្ថាប័ន រួមទាំងលំហូរសាច់ប្រាក់ ការវិនិយោគ បំណុល និងកម្រិតដើមទុន និងធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រអំពីកន្លែងដែលត្រូវបែងចែកធនធាន ដើម្បីបំពេញគោលដៅរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ វដ្តនៃការគ្រប់គ្រងហិរញ្ញវត្ថុគឺជាដំណើរការមានដូចជា÷ ការធ្វើផែនការថវិកា ការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយ ការគ្រប់គ្រងសាច់ប្រាក់ ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ ការបិទបញ្ជីគណនេយ្យ និងការតាមដានត្រួតពិនិត្យការអនុវត្តថវិកា។

សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋក្នុងដំណើរការកៀរគរចំណូល និងការទូទាត់ចំណាយរបស់ខ្លួន ពោលគឺលើកកម្ពស់ប្រសិទ្ធភាពចំណូល និងចំណាយ ហើយចំណាយត្រូវប្រកបដោយវិចារណកម្មត្រឹមត្រូវ ដើម្បីរួមចំណែកឱ្យសេដ្ឋកិច្ចមានការរីកចម្រើន។ សកម្មភាព និងវិធានការនៃហិរញ្ញវត្ថុសាធារណៈរួមមាន÷ ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងពន្ធអាករ ការគ្រប់គ្រងចំណូល-ចំណាយសាធារណៈ ការរៀបចំប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ ការគ្រប់គ្រងលទ្ធកម្ម ការគ្រប់គ្រងកម្ចីក្នុងនិងក្រៅប្រទេស ការធានារ៉ាប់រង ការសន្សំក្នុងស្រុក ការរៀបចំមូលនិធិចូលនិវត្តន៍ និងការលើកកម្ពស់វិនិយោគិនជាដើម។

**ជារួម÷** ការគ្រប់គ្រងហិរញ្ញវត្ថុជាផ្នែកមួយដ៏សំខាន់ក្នុងការជួយស្ថាប័នលើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រាល់ការអនុវត្តចំណូល ការអនុវត្តចំណាយ និងការគ្រប់គ្រងថវិការបស់ស្ថាប័នធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**អត្ថបទ÷** កញ្ញា **អ៊ុន សៀកមុី**

***ឯកសារយោង÷១.*** *អនុក្រឹត្យលេខ ២៨៩ អន.ក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ*

***២.*** *ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ* ***អ.ស.ហ.***

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website